## ខ្លឹមសារសង្ខេប
## សេចក្ដីសម្រេចលើញត្តិជំទាស់បឋម ស្ដីពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុងរបស់ អវតក

១. ក្នុងដំណើរការក្ដី ភាគីនីមួយៗសំអាងលើច្បាប់ ដែលនឹងត្រូវសុំឲ្យចៅក្រមសម្រេច ឲ្យប្រយោជន៍មកខ្លួន។ លោក **នួន ជា** បានអះអាងថា ច្បាប់ ស្ដីពី អវតក ត្រូវបានអនុម័តដោយសភា ហើយមានតែសភាទេ ត្រូវអនុម័តវិធានផ្ទៃក្នុង នៃ អវតក។ ការណ៍ដែល អង្គជំនុំជម្រះទាំងអស់រួមគ្នា (ECCC Plenary Meeting) អនុម័តវិធានផ្ទៃក្នុង វាជាការងារហួសសមត្ថកិច្ច (*Utra Vire*) អាស្រ័យហេតុនេះ វិធានផ្ទៃក្នុងត្រូវគ្មានសុពលភាព (void) (កថាខ័ណ្ឌ ទី ៣)។

២. អង្គជំនុំជម្រះសាលាដំបូង (សាលាដំបូង) អះអាងតបថា គ្មានច្បាប់ឬបទប្បញ្ញត្តិ នៃ អវតក ដែលហាមឃាត់ ការអនុម័តវិធានផ្ទៃក្នុងដូចនេះទេ។ តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ក៏អនុវត្តស្រដៀងនេះដែរ (កថា.ទី៧)។ សាលាដំបូង បានដកស្រង់ខ្លឹមសារនៃសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដើម្បីគាំទ្រការអះអាងនេះ ដែលមានសេចក្ដីថា៖

> *"វិធានផ្ទៃក្នុង..បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង.......វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌ...ដូចនេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចំបង ដែលយើងគួរនឹងយកមកពិនិត្យ ក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អវតក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា"*។[1]

<u>**កំណត់សំគាល់**</u>៖ **ក**. ញត្តិនេះ ធ្វើឡើងដោយ លោក **នួន ជា** ក្នុងដំណើរត្រៀមសវនាការ ដែលក្នុងអំឡុងពេលនេះ ជនជាប់ចោទអាចលើកបញ្ហាមួយចំនួនស្នើសុំឲ្យចៅក្រមវិនិច្ឆ័យសម្រេច។ **នួន ជា** ស្នើសុំឲ្យ មោឃភាពតាមវិធានផ្ទៃក្នុងវិធានទី ៨៩(១.គ) (Preliminary Objection)។ តាមខ្លឹមសារវិធាននេះ ការសុំមោឃភាពនីតិវិធីណាមួយ (nullity of procedural acts) សំដៅលើកិច្ចក្រោយពីមានការបញ្ជូនទៅជំនុំជម្រះ (indictment) ។ វិធានផ្ទៃក្នុង ត្រូវបានអនុម័តក្នុងខែ មិថុនា ឆ្នាំ២០០៧ មុនដីកា

---

[1] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព (សាធារណៈ) ឯកសារ D55/1/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ២០០៨ កថាខ័ណ្ឌ ១៤។

បញ្ជូនទៅជំនុំជម្រះ។ ក្នុងន័យនេះ សាលាដំបូង ចង់មានន័យថា ញត្តិនេះធ្វើខុសពេលវេលា ហួសវិសាលភាពនៃវិធានពាក់ព័ន្ធ ដូចនេះបដិសេធមិនពិនិត្យសំណើនេះ (កថាខ័ណ្ឌទី ៥)។ **ខ**. ខ្លឹមសារដកស្រង់ (quotation) បង្ហាញថា វិធានផ្ទៃក្នុងជាវិធានពិសេស (*lex specialis*) ដែលត្រូវអនុវត្តនាពេលមានភាពខុសគ្នារវាងវា និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ទ្រឹស្តីវិធានពិសេសនេះ សម្រាប់ជួយក្នុងការបកស្រាយច្បាប់ ដោះស្រាយនូវភាពមិនស៊ីសង្វាក់គ្នារវាងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ។

ECCC Trial Chamber, Case 002, Decision on NUON Chea ‘s Preliminary Objection Alleging the Unconstitutional Character of the ECCC Internal Rules, E51/14, 8 August 2011 (Public)